# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ខេត្តសៀមរាប**

លេខៈ ........០៧៧..................មកប

**ជម្រាបមក**

**លោក/លោកស្រី ម្ចាស់ ឬនាយក ខហ្វហ្វី ខនសិប (ខេមបូឌា) លីមីធីត (សាខាខេត្តសៀមរាប)**

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។

**យោង** ៖ លិខិតលេខ ២០០៤២១៥៣៩២ ចុះថ្ងៃទី២១ ខែ មេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខហ្វហ្វី ខនសិប (ខេមបូឌា) លីមីធីត (សាខាខេត្តសៀមរាប) ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក/លោកស្រី ម្ចាស់ ឬនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១២នាក់ (ស្រី ៤នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ២៨៣នាក់ (ស្រី១២៥នាក់) រយៈពេលចំនួន ៦០ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០។ ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោក/លោកស្រី ម្ចាស់ ឬនាយក** ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី **លោក/លោកស្រី ម្ចាស់ ឬនាយក** ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការ។

អាស្រ័យដូចនេះ សូម **លោក/លោកស្រី ម្ចាស់ ឬនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោក/លោកស្រី ម្ចាស់ ឬនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃច័ន្ទ ១៣កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦.....

សៀមរាប ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០២០

**ត.ប. រដ្ឋមន្ត្រី**

**ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ច័ន្ទ សុខុមចិត្តា**

ចម្លងជូនៈ

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍)
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលខេត្ត